ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តបាត់ដំបង**
**ការិយាល័យអភិវឌ្ឍន៍សហគមន៍កសិកម្ម**

# របាយការណ៍
# ស្តីពី ការបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០១៦

## ១ ស្ថានភាពរួម

ខេត្តបាត់ដំបងមានស្រុកចំនួន ១៣ និង ក្រុង១ ហើយមានវិសាលភាពគ្របដណ្តប់លើផ្ទៃដីធំទូលាយសម្រាប់ប្រកបរបរកសិកម្ម ។ បើតាមការវិភាគក្សេត្របរិស្ថានដាំដុះ យើងចែកជាបួនតំបន់ធំគឺៈ តំបន់នៅជុំវិញបឹងទន្លេសាប, តំបន់វាលទំនាប, តំបន់ខ្ពង់រាប និងតំបន់អភិរក្សព្រៃឈើដែលស្ថិតនៅទិសពាយព្យនៃប្រទេសកម្ពុជា។ ប្រជាជនភាគច្រើនប្រកបរបរកសិកម្មមានដូចជាៈ ការធ្វើស្រែ ចំការ និងចិញ្ចឹមសត្វ ដើម្បីជួយទ្រទ្រង់ជីវភាពគ្រួសារ និងសង្គម។ ការិយាល័យអភិវឌ្ឍន៍សហគមន៍កសិកម្ម នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តបាត់ដំបង បានយកចិត្តទុកដាក់ជួយដល់ប្រជាកសិករ ដោយរួមសហការនឹងអង្គការនានាដូចជា អង្គការក្រុមអភិវឌ្ឍន៍ភូមិ អង្គការទស្សនៈពិភពលោក និងអង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ជាដើម។

## ២ ស្ថានភាពបុគ្គលិក

ការិយាល័យអភិវឌ្ឍន៍សហគមន៍កសិកម្ម នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តបាត់ដំបងមានមន្ត្រីបំពេញការងារក្នុងការិយាល័យសរុបចំនួន ១២នាក់ ស្ត្រី ១នាក់ សម្រាប់ចុះពង្រឹងសហគមន៍កសិកម្ម និងចូលរួមមហាសន្និបាតតាមបណ្តាសហគមន៍កសិកម្ម។ ក្នុងចំណោមមន្ត្រីរាជការទាំង ១២នាក់នោះត្រូវបានបែងចែកគឺ មន្ត្រីចំនួន ៤នាក់ទទួលបន្ទុកប្រចាំការនៅការិយាល័យថ្នាក់ខេត្ត, មន្ត្រីចំនួន ៥នាក់ សម្រាប់ចុះចល័តតាមបណ្តាស្រុកដែលមិនមានមន្ត្រីប្រចាំការ និងមន្ត្រី ចំនួន ៣នាក់ត្រូវបានបែងចែកឲ្យទៅប្រចាំការនៅតាមស្រុកដូចខាងក្រោមៈ

- ប្រចាំការនៅស្រុកថ្មគោល មានមន្ត្រី ១នាក់
- ប្រចាំការនៅស្រុកបវេល មានមន្ត្រី ១នាក់
- ប្រចាំការនៅស្រុកមោងឫស្សី មានមន្ត្រី ១នាក់ ។

ការិយាល័យអភិវឌ្ឍន៍សហគមន៍កសិកម្ម ក៏បានសហការជាមួយការិយាល័យកសិកម្មស្រុកទាំង១៣ និងក្រុង១ ដើម្បីរួមគ្នាជួយអភិវឌ្ឍសហគមន៍កសិកម្មតាមបណ្តាលស្រុក និងក្រុងផងដែរ ។

## ៣ សកម្មភាព និងលទ្ធផលសម្រេចបាន

### ក សន្និបាតបូកសរុបការងារសហគមន៍កសិកម្មប្រចាំឆ្នាំ

បានរៀបចំសន្និបាតបូកសរុបការងារអភិវឌ្ឍន៍សហគមន៍កសិកម្មទូទាំងខេត្តប្រចាំឆ្នាំ ២០១៥ ចំនួន ១លើក នៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តដោយមានការចូលរួមពីមន្ត្រី អាជ្ញាធរឃុំ-ស្រុក អង្គការដៃគូអភិវឌ្ឍន៍ និងសហគមន៍កសិកម្មសរុបចំនួន ១០៩នាក់ ស្ត្រី ១៥នាក់ ក្នុងនោះតំណាងសហគមន៍កសិកម្មមានចំនួន ៦៤នាក់ ស្ត្រី ១១នាក់ ត្រូវជា ៦២សហគមន៍ ។

### ខ ការចុះបញ្ជីសហគមន៍កសិកម្ម

បានចុះបញ្ជីសហគមន៍កសិកម្មថ្មីបានចំនួន ៥សហគមន៍ ដូចជា៖

- សហគមន៍កសិកម្មកកោះ នៅឃុំកកោះ ស្រុកមោងឫស្សី មានសមាជិកសរុបចំនួន ៣១នាក់ ស្រី ២១នាក់ និងមានចំនួនភាគហ៊ុន ៤១ហ៊ុន, តម្លៃ ៣០,០០០រៀលក្នុងមួយហ៊ុន ស្មើនឹងទឹកប្រាក់សរុបចំនួន ១,២៣០,០០០រៀល
- សហគមន៍កសិកម្មរំដួលភ្នំព្រឹក នៅឃុំអូររំដួល ស្រុកភ្នំព្រឹក មានសមាជិកសរុបចំនួន ៣០នាក់ ស្រី ២៨នាក់ និងមានភាគហ៊ុនចំនួន ៣០ហ៊ុន, តម្លៃ ១០០,០០០រៀលក្នុងមួយហ៊ុន ស្មើនឹងទឹកប្រាក់សរុបចំនួន ៣,០០០,០០០រៀល
- សហគមន៍កសិកម្មសម្រស់មុខរាហ៍ នៅឃុំមុខរាហ៍ ស្រុករុក្ខគិរី មានសមាជិកសរុបចំនួន ៥៨នាក់ ស្រី ២១នាក់ និងមានភាគហ៊ុនចំនួន ៦២ហ៊ុន, តម្លៃ ៥០,០០០រៀលក្នុងមួយហ៊ុន ស្មើនឹងទឹកប្រាក់សរុបចំនួន ៣,១០០,០០០រៀល
- សហគមន៍កសិកម្មពន្លឺថ្មីឃុំព្រៃត្រឡាច នៅឃុំព្រៃត្រឡាច ស្រុករុក្ខគិរី មានសមាជិកសរុបចំនួន ៦២នាក់ ស្រី ៤១នាក់ និងមានភាគហ៊ុនចំនួន ៦៩ហ៊ុន, តម្លៃ ៥០,០០០រៀលក្នុងមួយហ៊ុន ស្មើនឹងទឹកប្រាក់សរុបចំនួន ៣,៤៥០,០០០រៀល
- សហគមន៍កសិកម្មបឹងព្រីង នៅឃុំបឹងព្រីង ស្រុកថ្មគោល មានសមាជិកសរុប ៣២នាក់ ស្រី ៦នាក់ និងមានភាគហ៊ុនចំនួន ១០០ហ៊ុន, តម្លៃ ៥០,០០០រៀលក្នុងមួយហ៊ុន ស្មើនឹងទឹកប្រាក់សរុប ៥,០០០,០០០រៀល ។

### គ ការចូលរួមមហាសន្និបាតរបស់សហគមន៍កសិកម្ម

បានចូលរួមជាគណៈអធិបតីក្នុងពិធីមហាសន្និបាតប្រចាំឆ្នាំរបស់សហគមន៍កសិកម្មចំនួន ១៩លើក ស្មើនឹង ២៤.៦៧% នៃចំនួនសហគមន៍សរុបក្នុងខេត្តក្នុងរួមមាន៖

- ស្រុកបាណន់៖ សហគមន៍កសិកម្មពន្លឺថ្មីក្តីសង្ឃឹមនៃកសិករ, ពន្លឺចែងមានជ័យ, ភ្នំក្រពើ, កន្ទឺ១កក្តីស្មើជលសារ, កន្ទឺ២សាមគ្គីបាណន់មានជ័យ
- ស្រុកសង្កែ៖ សហគមន៍កសិកម្មចម្រើនផលរាំងកេសី
- ស្រុកមោងឫស្សី៖ សហគមន៍កសិកម្មកកោះ
- ស្រុករុក្ខគិរី៖ សហគមន៍កសិកម្មសម្រស់មុខរាហ៍ និង ពន្លឺថ្មីឃុំព្រៃត្រឡាច
- ស្រុកឯកភ្នំ៖ សហគមន៍កសិកម្មរស្មីស្ដីក្រោម
- ស្រុកថ្មគោល៖ សហគមន៍កសិកម្មបឹងព្រីង
- ស្រុកបវេល៖ សហគមន៍កសិកម្មមានជ័យអំពិលប្រាំដើម
- ស្រុកភ្នំព្រឹក៖ សហគមន៍កសិកម្មពន្លឺថ្មីសាមគ្គី បួរសាមគ្គីមានជ័យ ពន្លឺថ្មីពេជ្រចិន្តា និង រំដួលភ្នំព្រឹក
- ស្រុកសំឡូត៖ សហគមន៍កសិកម្មតាតោកទល់ដែន, សម្រស់កំពង់ល្ពៅ, និង មានជ័យរស្មីរុងរឿង។

### ឃ ការផ្សព្វផ្សាយ និងបណ្តុះបណ្តាល

បានផ្សព្វផ្សាយ និងបណ្តុះបណ្តាលដល់សហគមន៍កសិកម្មសរុបបានចំនួន ១៨លើក ក្នុងនោះរួមមាន៖

- បានផ្សព្វផ្សាយគោលគំនិត និងច្បាប់សហគមន៍កសិកម្មចំនួន ៥លើក មានអ្នកចូលរួមសរុបចំនួន ៣៥៣នាក់ ស្ត្រី ១៨៩នាក់ ស្ថិតនៅឃុំកកោះ ស្រុកមោងឫស្សី, ឃុំព្រៃត្រឡាច និងឃុំមុខរាហ៍ ស្រុករុក្ខគិរី, ឃុំអូររំដួល ស្រុកភ្នំព្រឹក និងឃុំបឹងព្រីង ស្រុកថ្មគោល
- បានផ្សព្វផ្សាយគំរូលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងគំរូសម្រាប់សហគមន៍កសិកម្មចំនួន ៥លើក មានអ្នកចូលរួមសរុបចំនួន ៣៥៣នាក់ ស្ត្រី ១៨៣នាក់ ស្ថិតនៅឃុំកកោះ ស្រុកមោងឫស្សី, ឃុំព្រៃត្រឡាច និងឃុំមុខរាហ៍ ស្រុករុក្ខគិរី, ឃុំអូររំដួល ស្រុកភ្នំព្រឹក និងឃុំបឹងព្រីង ស្រុកថ្មគោល

- បានផ្សព្វផ្សាយប្រកាសលេខ ១៨៥ ប្រក.កសក របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពី លក្ខន្តិកៈគំរូ និងបទបញ្ជាផ្ទៃក្នុងគំរូសម្រាប់សហគមន៍កសិកម្មចំនួន ២លើក ដែលមានអ្នកចូលរួមសរុបចំនួន ៤៣នាក់ ស្រី ១៨នាក់ មកពីសហគមន៍កសិកម្មចំនួន ១៥សហគមន៍ដែលគាំទ្រដោយអង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍

- បានសម្របសម្រួលវគ្គរៀបចំរបាយការណ៍ប្រចាំឆ្នាំរបស់សហគមន៍កសិកម្មចំនួន ២លើក ដែលមានអ្នកចូលរួម ២៧នាក់ ស្រី ១៤ នាក់មកពីសហគមន៍កសិកម្មចំនួន ៥សហគមន៍ដែលគាំទ្រដោយអង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍

- បានសម្របសម្រួលវគ្គបណ្តុះបណ្តាលស្តី ការចុះបញ្ជីគណនេយ្យសហគមន៍កសិកម្មចំនួន ១វគ្គ មានអ្នកចូលរួម ១០នាក់ ស្រី ៦នាក់មកពីសហគមន៍កសិកម្មចំនួន ២សហគមន៍នៅស្រុកភ្នំព្រឹកដែលគាំទ្រដោយអង្គការទស្សនៈពិភពលោក

- បានសម្របសម្រួលវគ្គបណ្តុះបណ្តាលស្តី ផែនការអាជីវកម្មចំនួន ១វគ្គ ដែលមានអ្នកចូលរួម ៣២នាក់ ស្រី ១៣នាក់ មកពីសហគមន៍កសិកម្មចំនួន ១១សហគមន៍ដែលគាំទ្រដោយអង្គកាតទស្សនៈពិភពលោក

- បានសម្របសម្រួលវគ្គបណ្តុះបណ្តាលស្តីពី សហគ្រិនភាពចំនួន ២វគ្គ ដល់ ១០សហគមន៍កសិកម្មនៅក្នុងស្រុកមោងឫស្សី និងស្រុកកំរៀងដែលគាំទ្រដោយអង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍។

## ខ ការពង្រឹងសមត្ថភាពមន្ត្រី

ថ្នាក់ដឹកនាំ និងមន្ត្រីការិយាល័យសរុបចំនួន ៥នាក់ បានចូលរួមវគ្គបណ្តុះបណ្តាលសរុបចំនួន ១១វគ្គ រួមមានៈ

- ថ្នាក់ដឹកនាំ និងមន្ត្រីការិយាល័យសរុបចំនួន ៣នាក់ បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ផែនការមុខជំនួញ និងការរៀបចំមហាសន្និបាតប្រចាំឆ្នាំរបស់សហគមន៍កសិកម្មរយៈពេល ២ថ្ងៃនៅអគ្គនាយកដ្ឋានកសិកម្ម

- ថ្នាក់ដឹកនាំ និងមន្ត្រីការិយាល័យសរុបចំនួន ២នាក់ បានចូលរួមសិក្ខាសាលាស្តីពី ការគ្រប់គ្រងវត្តមានមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា និងការណែនាំលើឯកសារពាក់ព័ន្ធនឹងការងារគ្រប់គ្រងបុគ្គលិក និងកិច្ចការរដ្ឋបាលរយៈពេល ២ថ្ងៃនៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត

- ថ្នាក់ដឹកនាំ និងមន្ត្រីការិយាល័យសរុបចំនួន ៣នាក់ បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពី បែបបទបច្ចេកទេស និងនីតិវិធីក្នុងការរៀបចំ និងអនុវត្តសម្រាប់ថវិកាកម្មវិធីរយៈពេល ៣ថ្ងៃនៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត

- មន្ត្រីការិយាល័យចំនួន ២នាក់ បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី បច្ចេកទេសក្រោយពេលប្រមូលផលរយៈពេល ៥ថ្ងៃនៅមន្ទីរកសិកម្មខេត្តបាត់ដំបង

- ថ្នាក់ដឹកនាំ និងមន្ត្រីការិយាល័យសរុបចំនួន ៣នាក់ បានចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោលស្តីពី របាយការណ៍ប្រចាំឆ្នាំ, ផែនការសកម្មភាព និងផែនការហិរញ្ញវត្ថុប្រចាំឆ្នាំរបស់សហគមន៍កសិកម្មរយៈពេល ២ថ្ងៃនៅអគ្គនាយកដ្ឋានកសិកម្ម

- មន្ត្រីការិយាល័យចំនួន ៣នាក់ បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ(GIS) រយៈពេល ៥ថ្ងៃ ក្នុងការអនុវត្តកម្មវិធីអភិវឌ្ឍន៍វិស័យពាណិជ្ជកម្មស្រូវធន់នឹងអាកាសធាតុ នៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត

- មន្ត្រីចំនួន ១នាក់ បានទទួលការបណ្តុះបណ្តាលស្តីពី ការត្រួតពិនិត្យសហគមន៍កសិកម្មរយៈពេល ១ថ្ងៃ

- មន្ត្រីចំនួន ១នាក់ បានទទួលការបណ្តុះបណ្តាលស្តីពី ការប្រើប្រាស់ និងការគ្រប់គ្រងអនុគេហទំព័រមន្ទីរកសិកម្មខេត្ត នៃគេហទំព័រនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មរយៈពេល ២ថ្ងៃនៅអគ្គនាយកដ្ឋានកសិកម្ម

- មន្ត្រីចំនួន ១នាក់ បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ផលិតកម្មដំណាំស្រូវ និងផលិតកម្មគ្រាប់ពូជស្រូវនៅវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា(កាឌី CARDI)

- មន្ត្រីចំនួន ១នាក់ បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការផ្សព្វផ្សាយគំរូលក្ខន្តិកៈថ្មីសម្រាប់សហគមន៍កសិកម្ម

- មន្ត្រីចំនួន ១នាក់ បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី កំណត់ប្រព័ន្ធក្សេត្របរិស្ថាន ។

## ច ការសហការ

បានសហការជាមួយអង្គការនានាចំនួន ១០អង្គការ, គម្រោងអភិវឌ្ឍន៍ចំនួន ២គម្រោង និងការិយាល័យជំនាញចំនួន ៣ការិយាល័យ និងនាយកដ្ឋាន ចំនួន ១អង្គភាពដែលកំពុងគាំទ្រដល់សហគមន៍កសិកម្មសរុបបានចំនួន ៨៦លើក រួមមានៈ

- អង្គការទស្សនៈពិភពលោកកម្ពុជា៖ បានសហការចំនួន ៧លើក រួមមាន ការចងក្រងជាបណ្ដាញសហគមន៍កសិកម្ម ២លើក, សម្របសម្រួលដឹកនាំសហគមន៍កសិកម្មធ្វើទស្សនកិច្ចសិក្សានៅសហគមន៍កសិកម្មក្នុងខេត្តកណ្ដាល ១លើក, វគ្គបណ្ដុះបណ្ដាលផែនការអាជីវកម្ម ១លើក, វគ្គបណ្ដុះបណ្ដាលការចុះបញ្ជីគណនេយ្យសហគមន៍ ១លើក, រៀបចំវេទិការពិភាក្សាអាជីវកម្មសហគមន៍កសិកម្មប្រចាំឆ្នាំ ១លើក, និងសម្របសម្រួលឆ្លុះបញ្ចាំងការអនុវត្តរបស់សហគមន៍កសិកម្មក្នុងស្រុកបាណន់ ១លើក

- អង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍៖ បានសហការចំនួន ៩លើក រួមមាន រៀបចំផែនការឆ្នាំ២០១៦ដល់សហគមន៍កសិកម្ម ១លើក, សម្របសម្រួលវគ្គរៀបចំរបាយការណ៍ប្រចាំឆ្នាំរបស់សហគមន៍កសិកម្ម ២លើក, ផ្សព្វផ្សាយលក្ខន្តិកៈគំរូ និងបទបញ្ជាផ្ទៃក្នុងគំរូសម្រាប់សហគមន៍កសិកម្ម ២លើក, វគ្គបណ្ដុះបណ្ដាលសហគ្រិនភាព ២លើក, និងកែប្រែលក្ខន្តិកៈសហគមន៍កសិកម្ម ២លើក

- អង្គការបន្ទាយស្រីប្រចាំខេត្តបាត់ដំបង៖ បានសហការចំនួន ១លើក ស្ដីពី ផលប្រយោជន៍ និងនីតិវិធីក្នុងការបង្កើតសហគមន៍កសិកម្មដល់តំណាងកសិករគំរូ និងបុគ្គលិកអង្គការ

- អង្គការ VSO (Volunteer Services Overseas) និងអង្គការក្រុមអភិវឌ្ឍន៍ភូមិ៖ បានសហការចំនួន ២លើក ក្នុងការសម្របសម្រួលដឹកនាំសហគមន៍កសិកម្មចំនួន ១០សហគមន៍ក្នុងខេត្តបាត់ដំបងដើម្បីធ្វើទស្សនកិច្ចសិក្សានៅសហគមន៍កសិកម្មសែនសុខទឹកថ្លាក្នុងខេត្តតាកែវ ១លើក និងពិគ្រោះយោបល់ស្វែងរកដំណោះស្រាយរួម ដើម្បីទប់ស្កាត់វិបត្តិស្រូវអង្គរនៅខេត្តបាត់ដំបង ១លើក

- អង្គការជីវិតថ្លៃថ្នូរ៖ បានសហការចំនួន ១លើក ដើម្បីចូលរួមជាវាគ្មិនផ្សព្វផ្សាយគោលនយោបាយសហគមន៍កសិកម្ម

- សមាគមន៍សិទ្ធិ និងការអភិវឌ្ឍអ្នកភូមិយើង និងសមាគមដើម្បីអភិវឌ្ឍន៍សហគមន៍ខ្មែរ៖ បានសហការចំនួន ១លើក ស្ដីពីផលិតកម្មកសិកម្មក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ

- អង្គការព្រហ្មវិហារធម៌៖ បានសហការចំនួន ១លើក ក្នុងការដឹកនាំសហគមន៍កសិកម្មក្នុងខេត្តពោធិ៍សាត់មកធ្វើទស្សនកិច្ចសិក្សានៅសហគមន៍កសិកម្មកសិករញញឹមក្នុងស្រុករតនមណ្ឌល

- អង្គការអភិវឌ្ឍន៍ និងភាពជាដៃគូក្នុងសកម្មភាព៖ បានសហការចំនួន ១លើក ក្នុងការដឹកនាំសហគមន៍កសិកម្មក្នុងខេត្តរតនៈគិរីមកធ្វើទស្សនកិច្ចសិក្សានៅសហគមន៍កសិកម្មសេដ្ឋកិច្ចបៃតងសំឡូត និងសហគមន៍កសិកម្មសម្រស់កំពង់ល្ពៅក្នុងស្រុកសំឡូត

- គម្រោងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រ និងបង្កើនផលិតភាពកសិកម្ម(RIAPIP)៖ បានសហការចំនួន ៣៩លើក ក្នុងការជំរុញផលិតកម្មពូជស្រូវ(ផ្ការំដួល)ដល់សហគមន៍កសិកម្មចំនួន ៥សហគមន៍ដោយផ្ដល់ជាប្រាក់កម្ចីដោយគ្មានការប្រាក់ និងវគ្គបណ្ដុះបណ្ដាលរួមមាន វគ្គបណ្ដុះបណ្ដាលស្ដីពីផលិតកម្មគ្រាប់ពូជស្រូវ ២លើក, វគ្គបណ្ដុះបណ្ដាលស្ដីពីការថែទាំគ្រឿងយន្តកសិកម្ម ២លើក និងការចុះសម្របសម្រួលត្រួតពិនិត្យការអនុវត្តបច្ចេកទេសផលិតកម្មស្រូវពូជតាមសហគមន៍ចំនួន ៣៥លើក ចាប់ពីការរៀបចំដីរហូតដល់ការប្រមូលផល និងស្តុកទុក

- កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ(ASPIRE)៖ បានសហការចំនួន ២០លើក រួមមាន ការចូលរួមវិភាគតម្រូវការកសិករចំនួន ៨លើកនៅស្រុកសង្កែ និងស្រុកថ្មគោល, សម្របសម្រួលសហគមន៍កសិកម្មក្នុងការចូលរួមការតាំងពិព័ណ៌ប្រចាំឆ្នាំ២០១៦ថ្នាក់ក្រោមជាតិស្តីពី ការផ្សព្វផ្សាយបច្ចេកទេសកសិកម្ម និងសម្ភារកសិកម្ម ១លើក, ប្រជុំរៀបចំផែនការសកម្មភាព ៤លើក, ដឹកនាំកសិករទស្សនកិច្ចសិក្សាលើស្រែបង្ហាញនៅខេត្តសៀមរាប ១លើក, និងចុះពិនិត្យការអនុវត្តរបស់កសិករគោលដៅគម្រោង ៥លើក, និងពិគ្រោះយោបល់បែងចែកតួនាទីមន្ត្រីផ្សព្វផ្សាយកសិកម្ម ១លើក

- ការិយាល័យសវនកម្ម នៃនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម៖ បានសហការចំនួន ១លើក ក្នុងការរៀបចំវគ្គបណ្តុះ បណ្តាលស្តីពី ការត្រួតពិនិត្យសហគមន៍កសិកម្មដល់គណៈកម្មាធិការត្រួតពិនិត្យចំនួន ២៣នាក់ ស្រី ៨នាក់ មកពីសហគមន៍កសិកម្មចំនួន ៨សហគមន៍

- ការិយាល័យអភិវឌ្ឍន៍មុខជំនួញ និងទីផ្សារ នៃនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម៖ បានសហការចំនួន ១លើក ដើម្បីសម្របសម្រួលដឹកនាំសហគមន៍កសិកម្មចំនួន ៩សហគមន៍មកពីខេត្តប៉ៃលិនធ្វើទស្សនកិច្ចសិក្សាក្នុងខេត្តបាត់ដំបង

- ការិយាល័យអប់រំ បណ្តុះបណ្តាល និងសហប្រតិបត្តិការអន្តរជាតិ នៃនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម៖ បានសហការចំនួន ២លើក ក្នុងការបណ្តុះបណ្តាលស្តីពី ការប្រកបមុខរបរផ្គត់ផ្គង់ធាតុចូលកសិកម្ម ១លើកនិង វគ្គបណ្តុះបណ្តាលរៀបចំរបាយការណ៍ប្រចាំឆ្នាំរបស់សហគមន៍កសិកម្ម ១លើក

- នាយកដ្ឋានកសិឧស្សាហកម្ម៖ បានសហការចំនួន ១លើក ក្នុងការសម្របសម្រួលសហគមន៍កសិកម្មចំនួន ២ ក្នុងស្រុកបាណន់ដើម្បីចូលរួមវេទិកាភ្ជាប់ទំនាក់ទំនងកសិករខ្នាតតូច និងទីផ្សារ ។

## ឆ ការជួបពិភាក្សាពិគ្រោះយោបល់

បានជួបពិភាក្សាពីស្ថានភាពទាក់ទងនឹងសហគមន៍កសិកម្មជាមួយអង្គការដៃគូ និងក្រុមហ៊ុននានាចំនួន ៧ស្ថាប័ន រួមមាន៖

- អង្គការអ្នកជិតខាងល្អ(Good Neighbors)៖ បានជួបពិភាក្សាចំនួន ២លើក ស្តីពី នីតិវិធីចងក្រងសហគមន៍កសិកម្ម និងរៀបចំផែនការបង្កើតសហគមន៍កសិកម្មចំនួន ២សហគមន៍នៅស្រុកឯកភ្នំសម្រាប់ឆ្នាំ ២០១៧
- រោងម៉ាស៊ីនស្រូវមាសស(White Gold)៖ បានជួបពិភាក្សាចំនួន ១លើក ស្តីពី ព័ត៌មានសហគមន៍កសិកម្មដែលធ្វើផលិតកម្មពូជស្រូវផ្ការំដួល
- អគ្គិសនីកម្ពុជា៖ បានជួបពិភាក្សាចំនួន ១លើក ស្តីពី ព័ត៌មានសហគមន៍កសិកម្មក្នុងការប្រើប្រាស់ម៉ាស៊ីនបូមទឹកស្រោចស្រពដំណាំស្រូវ ដើម្បីរៀបចំគម្រោងតភ្ជាប់ចរន្តអគ្គិសនីដល់វាលស្រែសហគមន៍ក្នុងតម្លៃ ៤៨០រៀល/គីឡូវ៉ាត់ម៉ោង
- សមាគមប្រជាជនកូរ៉េក្នុងបាត់ដំបង និងប៉ៃលិន៖ បានជួបពិភាក្សាចំនួន ២លើក ស្តីពី នីតិវិធីបង្កើតសហគមន៍កសិកម្មនៅឃុំត្រែង ស្រុករតនមណ្ឌល
- អង្គការVSO(Volunteer Services Overseas)៖ បានជួបពិភាក្សាចំនួន ៣លើក ស្តីពី ការរៀបចំមេរៀនចុះបញ្ជីគណនេយ្យ សម្រាប់សហគមន៍កសិកម្ម ១លើក, ការរៀបចំដំណើរទស្សនកិច្ចរបស់សហគមន៍កសិកម្ម ១លើក, និងការសិក្សាពីស្ថានភាពសហគមន៍កសិកម្ម ១លើក
- មជ្ឈមណ្ឌលស្រាវជ្រាវ និងផ្សព្វផ្សាយកសិកម្មមូលដ្ឋាន(ឡារីក)៖ បានជួបពិភាក្សាចំនួន ១លើក ស្តីពី ការស្វែងយល់ពីសហគមន៍កសិកម្មដែលផលិតស្រូវពូជនៅក្នុងខេត្តបាត់ដំបង

- ក្រុមហ៊ុនអាគ្រីបាឌី(Agribuddy)៖ បានជួបពិភាក្សាចំនួន ២លើក ស្តីពី ផែនការរៀបចំសិក្ខាសាលាបណ្តុះបណ្តាលគ្រូបង្គោលតាមសហគមន៍កសិកម្មក្នុងការប្រើប្រាស់កម្មវិធីអាគ្រីបាឌីតាមរយៈទូរស័ព្ទស្មាតហ្វូន(Smart Phone) អំពីទិន្នន័យកសិកម្ម ។

## ៥ ស្ថិតិសហគមន៍កសិកម្ម

តារាងសង្ខេបទិន្នន័យសហគមន៍កសិកម្មតាមស្រុក/ក្រុង

| ល.រ | ស្រុក/ក្រុង | ចំនួនសហគមន៍ | សមាជិកសហគមន៍ | | អ្នកដឹកនាំសហគមន៍ | | ដើមទុន (រៀល) |
|---|---|---|---|---|---|---|---|
| | | | សរុប (នាក់) | ស្ត្រី (នាក់) | សរុប (នាក់) | ស្ត្រី(នាក់) | |
| ១ | ស្រុកមោងឫស្សី | 7 | 821 | 420 | 64 | 17 | 231,571,200 |
| ២ | ស្រុករុក្ខគិរី | 4 | 268 | 167 | 34 | 17 | 23,290,000 |
| ៣ | ស្រុកគាស់ក្រឡ | 8 | 1,381 | 707 | 76 | 24 | 405,810,500 |
| ៤ | ស្រុកសង្កែ | 6 | 692 | 291 | 51 | 13 | 356,619,180 |
| ៥ | ក្រុងបាត់ដំបង | 2 | 172 | 123 | 13 | 8 | 64,422,400 |
| ៦ | ស្រុកឯកភ្នំ | 2 | 244 | 147 | 16 | 7 | 100,380,609 |
| ៧ | ស្រុកថ្មគោល | 6 | 354 | 190 | 45 | 13 | 57,067,300 |
| ៨ | ស្រុកបវេល | 6 | 913 | 415 | 51 | 22 | 528,202,780 |
| ៩ | ស្រុកភ្នំព្រឹក | 6 | 630 | 319 | 49 | 25 | 519,441,000 |
| ១០ | ស្រុកកំរៀង | 5 | 838 | 414 | 40 | 16 | 766,056,760 |
| ១១ | ស្រុកសំពៅលូន | 6 | 744 | 477 | 44 | 18 | 1,069,527,920 |
| ១២ | ស្រុកសំឡូត | 6 | 1,674 | 1,160 | 65 | 29 | 844,418,300 |
| ១៣ | ស្រុករតនមណ្ឌល | 5 | 651 | 342 | 51 | 16 | 399,763,250 |
| ១៤ | ស្រុកបាណន់ | 8 | 1,302 | 725 | 69 | 22 | 976,842,120 |
| សរុប | | 77 | 10,684 | 5,897 | 668 | 247 | 6,343,413,319 |

### ដ្យាក្រាមទី១ ចំនួនសហគមន៍កសិកម្មផ្អែកតាមទំហំទ្រព្យសកម្មសរុប



### ដ្យាក្រាមទី ២ ចំនួនសហគមន៍កសិកម្មផ្អែកតាមប្រភេទទ្រព្យសម្បត្តិ




### ដ្យាក្រាមទី ៣ ចំនួនសហគមន៍កសិកម្មផ្អែកតាមភាពដំណើរការមុខរបរ




### ដ្យាក្រាមទី ៤ ចំនួនសហគមន៍កសិកម្មផ្អែកតាមប្រភេទមុខរបរ



## ៤ បញ្ហាប្រឈម និងដំណោះស្រាយ

- អ្នកដឹកនាំសហគមន៍កសិកម្មមួយចំនួនអសកម្ម
- សហគមន៍កសិកម្មភាគច្រើនមិនទាន់មានរបាយការណ៍ប្រចាំឆ្នាំ
- សហគមន៍កសិកម្មភាគច្រើនមិនទាន់មានផែនការអាជីវកម្មសម្រាប់ប្រតិបត្តិការ
- សហគមន៍កសិកម្មភាគច្រើនមិនទាន់បានធ្វើមហាសន្និបាត
- សមត្ថភាពថ្នាក់ដឹកនាំសហគមន៍ក្នុងការកត់ត្រាបញ្ជីគណនេយ្យនៅមានកម្រិត ។

## ៥ សំណូមពរ

- ស្នើសុំវគ្គបណ្តុះបណ្តាលជំនាញគណនេយ្យដល់មន្ត្រីការិយាល័យដើម្បីបណ្តុះបណ្តាលបន្តដល់សហគមន៍កសិកម្ម។

## ៦ ទិសដៅបន្ត

- បង្កើតសហគមន៍កសិកម្មថ្មី និងបន្តតាមដានសកម្មភាពសហគមន៍
- ជួយអន្តរាគមន៍ដល់សហគមន៍កសិកម្មដែលជួបបញ្ហា និងពង្រឹងសហគមន៍កសិកម្មដែលនៅមានភាពទន់ខ្សោយ
- រៀបចំសន្និបាតបូកសរុបការងារសហគមន៍កសិកម្មទូទាំងខេត្តប្រចាំឆ្នាំ ២០១៦
- រៀបចំវគ្គបណ្តុះបណ្តាលស្តីពីផែនការមុខជំនួញ និងការរបៀបរៀបចំរបាយការណ៍ប្រចាំឆ្នាំរបស់សហគមន៍កសិកម្ម
- ផ្លាស់ប្តូរវិញ្ញាបនបត្រទទួលស្គាល់សហគមន៍កសិកម្មតាមគំរូថ្មី
- បន្តសហការជាមួយអង្គការនានា
- បន្តសហការជាមួយគម្រោងអភិវឌ្ឍន៍នានា ដូចជា ASPIRE និង RIAPIP ។

បាត់ដំបង,ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ២០១៦

អ្នករៀបចំរបាយការណ៍

ឆុំ សុភក្រ្តា

បានឃើញ និងឯកភាព

បាត់ដំបង,ថ្ងៃទី២៦ ខែ ធ្នូ ឆ្នាំ២០១៦

**ប្រធានការិយាល័យ**

គា ឈុន

បានឃើញ និង ឯកភាព

បាត់ដំបង,ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៦

**ប្រធានមន្ទីរ**

ឈឹម_វជិរា